# កំណាយស្រះសង់ឆ្នាំ១៩៦៤

នៅដើមទសវត្សទី៦០មានការស្រាវជ្រាវជាច្រើន ចាប់ផ្ដើមនៅក្នុងតំបន់អង្គរដូចជាការ កំណាយស្រាវជ្រាវ និងការជួសជុលប្រាសាទជាដើម។ នៅឆ្នាំ ១៩៨៨ មានការបោះពុម្ពរបស់លោក Paul Courbin ដែលមានចំណងជើងថា « La fouille du Sras-Srang à Angkor[១]» ដែលមានន័យជាភាសាខ្មែរថា " ការកំណាយនៅស្រះស្រង់ក្នុងតំបន់អង្គរ " ដោយអត្ថបទបោះពុម្ពផ្សាយរបស់លោកមានចំនួន៥សន្លឹក។ គួរបញ្ជាក់ដែរថា ការកំណាយនៅស្រះស្រង់នេះ ដឹកនាំដោយលោក Bernard-Philippe Groslier និងបាន សហការជាមួយបុរាណវិទូផ្សេងទៀត ដែលមានលោក Paul Courbin ជាជំនួយការ។ អត្ថបទនេះបានបោះពុម្ពះអំឡុង ២០ឆ្នាំក្រោយ ការធ្វើកំណាយ នៅឆ្នាំ១៩៦៤។ នៅឆ្នាំ២០១២ មានស្នាដៃស្រាវជ្រាវថ្នាក់អនុបណ្ឌិតរបស់ លោកស្រី Alice VIERSTRAETE ដែលមានចំណងជើងថា « Révision des fouilles du Srah Srang à la lumière de nouveaux documents d'archives conservés à Paris[២]» ដែលមានន័យជាភាសាខ្មែរថា "ការសិក្សាឡើងវិញអំពីការកំណាយនៅស្រះស្រង់ ដែលរៀបរៀងជាឯកសារថ្មីតម្កល់ទុកនៅទីក្រុងបារីស" ។ លោកស្រីបានពន្យល់ និងបង្ហាញជាលំដាប់ លំដោយនូវ បញ្ជីវត្ថុដែលបានរកឃើញ និងការសិក្សាអំពីវត្ថុទាំងនោះ ។

នៅក្នុងអត្ថបទរបស់លោក Paul Courbin គាត់បានបង្ហាញអំពីវិធីសាស្ត្រនៃការកំណាយនៅស្រះស្រង់របស់លោក B.P Groslier ។ វិធីសាស្ត្រនេះដែរ លោក B.P Groslier ក៏ធ្លាប់បានប្រើពេលកំណាយនៅរាជវាំងអង្គរធំ ដោយហៅថា វិធីសាស្ត្រ Wheeler។[៣] គួរបញ្ជាក់ដែរថា Wheeler គឺជាឈ្មោះបុរាណវិទូជនជាតិអង់គ្លេសម្នាក់ ដែល ឈ្មោះពេញរបស់គាត់គឺ Mortimer Wheeler។ គាត់ជាអ្នករកឃើញ និងប្រើប្រាស់វិធីសាស្ត្រនេះមុនគេបង្អស់ ហើយក៏ជាវិធីសាស្ត្រល្បីល្បាញមួយនាទសវត្សរ៍ទី៦០ផងដែរ។ ចំពោះវិធីសាស្ត្រនេះ

---

[១] សូមមើល Paul Courbin, La fouille du Sras-Srang, 1988.

[២] សូមមើល Alice VIERSTRAETE, Révision des fouilles du Srah Srang à la lumière de nouveaux documents d'archives conservés à Paris, 2012.

[៣] Courbin,1988, p.21.

អត្ថបទដោយ៖ អេង តុលា

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

គឺជីករណ្តៅជាពង់ការ៉េសងខាង និងទុកផ្លូវដើរនៅកណ្តាល។[៤] ការប្រើប្រាស់វិធីសាស្ត្រនេះគឺដើម្បីពិនិត្យមើល ស្រទាប់ដី ហើយក៏អាចរកឃើញវត្ថុជាច្រើន ព្រមទាំងអាចកំណត់ដឹងអំពីកាលប្បវត្តិនៃស្ថានីយនេះដែរ ។[៥]

ការកំណាយនៅឆ្នាំ១៩៦៤នោះ គឺកាយរណ្តៅចាប់ពីជ្រុងខាងលិចនៃស្រះស្រង់ដែលបច្ចុប្បន្នជាសួនជាប់នឹងផ្លូវធំ។ ការកំណាយ បានរកឃើញវត្ថុជាច្រើនដូចជា កុលាលភាជន៍, វត្ថុអំពីដែក, វត្ថុអំពីសំរិទ្ធ សំណ និងព្រះពុទ្ធរូបអំពីថ្មកក់ផ្សេងៗទៀត។[៦]

តាមរយៈអត្ថបទរបស់លោក Paul Courbin ស្រទាប់ដីនៅស្រះស្រង់ បានបែងចែកជា ៥ស្រទាប់ផ្សេងៗគ្នា ពោលគឺ ចាប់ ពីស.វទី១០ រហូតដល់ស.វទី១៤នៃគ.ស[៧] និងបើតាមលោក J. Dumarçay ដែលបានសិក្សាក្រោយមកទៀត តាមរយៈវត្ថុដែលកំណាយឃើញស្ថានីយនេះមានអាយុប្រហែលចាប់ពី ស. វទី ៩ ដល់ទី១៥ ។

ចំពោះស្រទាប់ដីទី១ អាចហៅបានថា ស្រះស្រង់ទី១ កសាងក្នុងរាជ្យរបស់ព្រះបាទរាជេន្ទ្រវរ្ម័ន ពាក់កណ្តាលស.វទី១០នៃគ.ស។ តាមរយៈសិលាចារឹក K.266 K.267 K.268 នៃប្រាសាទបាតជុំ[៨]បានបង្ហាញអំពីស្រះពិសិដ្ឋមួយ ប្រហែលជាស្រះស្រង់នេះឯង[៩] ហើយ
តាមរយៈការសន្និដ្ឋានរបស់លោក G. Coedès ស្រះស្រង់នេះគឺជាស្រះទឹកនៃកុដិស្វរ។[១០] ស្រះស្រង់ទី១នេះ កសាងនៅលើស្រះធម្មជាតិដែលមាននៅទីនោះស្រាប់។

---

[៤] Courbin, 1988, p.24

[៥] Alice, 2012, p.38.

[៦] *ibid,*

[៧] Courbin, 1988, p. 22

[៨] ប្រាសាទពុទ្ធសាសនានិកាយទន្ទាក់ មួយនាសតវត្សទី១០ស្ថិតនៅក្បែរស្រះស្រង់ខាងត្បូង ៣០០ម៉ែត្រ ។

[៩] Aymonier , 1904,p.13.

[១០] Kuṭīśvara គឺជាឈ្មោះនៃស្រុកសម័យបុរាណមួយ ដែលបច្ចុប្បន្នជាតំបន់ប្រាសាទបន្ទាយក្តី និងនៅក្បែរនោះមានប្រាសាទតួប៉មបី ដែលតួប៉មចាស់បំផុតកសាងក្នុងសតវត្សទី៩ ដែលមានឈ្មោះថា Kuṭīśvara ឬកុដិស្វរ ។

អត្ថបទដោយ៖ អេង តុលា

*រីឯស្រទាប់ដីទី២ ជាស្រទាប់ដែលគេប្រើប្រាស់ទាក់ទងនឹងជំនឿសាសនា។ គេរកឃើញវត្ថុសិល្បៈជាច្រើនដែលបានកប់ ក្នុងក្រឡ ឬកោដ្ឋដែលហៅថាជាទីតាំងបញ្ចុះសព* (Nécropole)*។ ក្នុងអត្ថបទរបស់លោក* Paul Courbin *បានបង្ហាញថា ស្រទាប់នេះអាចមានអាយុកាលនៅស.វទី១១នៃគ.ស។*[១១] *នៅក្នុងជំនឿអ្នកស្រុកអាស៊ីអាគ្នេយ៍បុរាណដែលបានទទួលឥទ្ធិពលពីឥណ្ឌាតែងតែប្រារព្ធពិធីបុណ្យពីរដង ដោយបូជាសពនឹងភ្លើង រួចហើយប្រមូលធាតុយកមកកប់ក្នុងកោដ្ឋជាមួយនឹងវត្ថុសំណែនផ្សេងៗទៀត។*[១២] *ស្រទាប់ទី២នេះគឺស្ថិតនៅ ភាគកណ្តាលនៃជ្រុងខាងលិចស្រះស្រង់ទី១។*

*ស្រទាប់ដីទី៣ គឺការតាំងទីសម្រាប់សិប្បកម្ម (រោងជាង)សម្រាប់កសាងប្រាសាទបន្ទាយក្តី និងស្រះស្រង់ទី២ក្នុងរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ នៅចុងស.វទី១២។*[១៣] *ក្នុងស.វទី១២នេះ មានការកសាងបន្ថែម និងពង្រីកបរិវេណជុំវិញស្រះស្រង់ រួមមាន កសាងជណ្តើរជុំវិញស្រះស្រង់ ផែនៅខាងមុខប្រាសាទបន្ទាយក្តី និងប្រាសាទកណ្តាលស្រះស្រង់។ ស្រទាប់នេះបានរកឃើញភាគច្រើនជា ឧបករណ៍ធ្វើអំពីដែក*[១៤] *ប្រហែលជាឧបករណ៍សម្រាប់ធ្វាក់សម័យនោះ ។*

*ស្រទាប់ទី៤នេះប្រហែលជាចាប់ផ្តើមនៅពាក់កណ្តាលស.វទី១៣ សម្រាប់ជាទីតាំងបញ្ចុះសព។*[១៥] *នៅក្នុងអត្ថបទរបស់លោក* Courbin *ស្រទាប់នេះពុំសូវមានដានច្បាស់លាស់ដូចស្រទាប់ទី២នោះទេ ប៉ុន្តែយើងអាចសិក្សាលើកុលាលភាជន៍ទាំងនោះ និងវត្ថុសិល្បៈដែលកប់នៅក្នុងកោដ្ឋ។ ការកំណាយរណ្តៅខាងមុខប្រាសាទបន្ទាយក្តីក្នុងឆ្នាំ ១៩៦៤នោះ ឃើញមានការកប់រូបបដិមាព្រះលោកេស្វរ និងប្រាជ្ញាបារមី ធ្វើអំពីសំរឹទ្ធិក្នុងរចនាបទបាយ័ន្តស.វទី១៣*[១៦] *និងវត្ថុធ្វើអំពីសំរឹទ្ធិ ជាច្រើនទៀត ដែលកប់ក្នុងក្រឡ ផ្សេងៗគ្នា ។*

---

[១១] Courbin, 1988, p.23

[១២] Alice, 2012, p.110.

[១៣] Courbin, 1988, p.24

[១៤] *សព្វថ្ងៃស្ថិតនៅក្នុងឃ្លាំងរបស់សារមន្ទីរជាតិភ្នំពេញ ។*

[១៥] Courbin, 1988, p.24

[១៦] *ibid,* Fig34-36.

*អត្ថបទដោយ៖ អេង តុលា*

ស្រទាប់ទី៨ គឺជាស្រទាប់ដែលអាចនិយាយបានថាជាសម័យកាលដែលស្រះស្រង់ឈប់មានការវិវត្តន៍ទៀតហើយ ប៉ុន្តែនៅបន្ត ការបញ្ចុះសពដដែល។[១៧] កុលាភាជន៍ដែលរកឃើញក្នុងស្រទាប់នេះ ភាគច្រើនជាកុលាលភាជន៍រូបសត្វក្នុងសម័យអង្គរ ប្រហែលស្ថិតក្នុងស.វទី១៣ ឬ១៤នៃគ.ស។ រីឯសំណៅនដែលបានរកឃើញក្នុងស្រទាប់នេះវិញឃើញមានជាវត្ថុអំពីសំរឹទ្ធិ រូបសត្វធ្វើអំពីថ្មភក់ និងក្រឡកោដ្ឋជាច្រើនទៀត។

ក្រោយពីការរកឃើញវត្ថុសិល្បៈយ៉ាងច្រើននេះ យើងអាចសន្និដ្ឋានបានថា ទីតាំងនេះជាទីតាំងដែលមានតឹកតាងប្រវត្តិសាស្ត្រយ៉ាងសំខាន់មួយក្នុងតំបន់អង្គរ ជាពិសេសជាទីតាំងបញ្ចុះសពក្នុងសម័យអង្គរ។ យើងក៏ធ្លាប់បានឃើញអំពីប្រភេទនៃស្ថានីយបញ្ចុះសពពីមុនមកដែរ ដូចជា នៅកោះតាមាស (យុគសំរឹទ្ធិ) ភូមិស្នាយ (យុគដែក) ព្រៃក្មេង (យុគដែក) និងស្ថានីយផ្សេងៗទៀត។




រូបលេខ១៖ រូបភាពពីលើអាកាសបង្ហាញអំពី ប្រាសាទបាតជុំ, ប្រាសាទ បន្ទាយក្តី, ប្រាសាទ កុដិស្វរ និងស្រះស្រង់ និងទីតាំងកំណាយនៅឆ្នាំ ១៩៦៤

[១៧] Courbin, 1988, p. 25

អត្ថបទដោយ៖ អេង តុលា



Bernard Groslier au Sras-Srang, 1964.

រូបលេខ២៖ រូបថតលោក B.P Groslier ពេលកំណាយឆ្នាំ ១៩៦៤



វ តុលា















រូបលេខ៤-៥៖ កុលាលភាជន៍ដែលបានរកឃើញក្នុងការធ្វើកំណាយ



អត្ថបទដោយ៖ អេង តុលា

រូបលេខ៦៖ កុលាលភាជន៍ដែលបានរកឃើញក្នុងការធ្វើកំណាយ



រូបលេខ៧៖ រូបសត្វអណ្តើកធ្វើអំពីថ្មភក់ដែលបានរកឃើញ

KHMER CIVILIZATION

## ឯកសារយោង

**Alice VIERSTRAETE**

2012. Révision des fouilles du Srah Srang (1964) à la lumière de nouveaux documents d’archives conservés à Paris (EFEO-Guimet). Mémoire de master II.

**Etienne AYMONIER**

1904. Le groupe d’Angkor et l’histoire

**Paul COURBIN**

1964. La fouille du Sras-Srang à Angkor. Doucments graphique de la conservation d’Angkor en 1963-1973